បោះពុម្ព និងផ្សព្វផ្សាយ

ដោយ គ.ជ.ប

ឆ្នាំ២០១៩

គ.ជ.ប

# សៀវភៅ

# សម្រាប់

# អ្នកបោះឆ្នោត



ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត

ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ អាណត្តិទី៣

ថ្ងៃអាទិត្យ ទី២៦ ខែឧសភា ឆ្នាំ២០១៩

# ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ អាណត្តិទី៣ ឆ្នាំ២០១៩




ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ អាណត្តិទី៣ ប្រព្រឹត្តទៅនៅ**ថ្ងៃអាទិត្យ ទី២៦ ខែឧសភា ឆ្នាំ២០១៩**។





១
តើសមាជិកក្រុមប្រឹក្សា មានអាណត្តិប៉ុន្មានឆ្នាំ ?
២
សមាជិកក្រុមប្រឹក្សា មានអាណត្តិ ៥ឆ្នាំ ហើយត្រូវបាន ផុតកំណត់នៅពេលក្រុមប្រឹក្សាថ្មីចូលកាន់តំណែង ។

# អ្នកបោះឆ្នោត




*អ្នកមានសិទ្ធិបោះឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា គឺ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់នៅក្នុងមុខតំណែងនៅក្នុងក្របខណ្ឌក្រុង ស្រុក ខណ្ឌនីមួយៗ ។*

# លក្ខខណ្ឌសម្រាប់អ្នកបោះឆ្នោត




ដើម្បីបោះឆ្នោតបាន អ្នកមានសិទ្ធិបោះឆ្នោត ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

- មានឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការ
- មានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតសម្គាល់ខ្លួនជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ នៅក្នុងមុខតំណែង ឬឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត ដែលនៅមានសុពលភាព ។

# ដំណើរការប្រព្រឹត្តទៅនៃការបោះឆ្នោត




*ការិយាល័យបោះឆ្នោតចាប់ផ្ដើមបើកឱ្យអ្នកបោះឆ្នោតចូលទៅបោះឆ្នោតចាប់ពី**ម៉ោង ៧:០០ នាទីព្រឹក ដល់ម៉ោង ៣:០០ នាទីរសៀល** ។ ការបោះឆ្នោតត្រូវធ្វើតែ ១ថ្ងៃ ។*



នៅពេលទៅដល់ការិយាល័យបោះឆ្នោត អ្នកបោះឆ្នោតត្រូវទៅរកមើលឈ្មោះរបស់ខ្លួនក្នុងបញ្ជីបោះឆ្នោត ដែលត្រូវបានបិទនៅមុខការិយាល័យបោះឆ្នោត ដើម្បីឱ្យប្រាកដថា ឈ្មោះរបស់ខ្លួនស្ថិតក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតនោះ ។






**អ្នកបោះឆ្នោតស្វែងរកឈ្មោះក្នុងបញ្ជីបោះឆ្នោត ដែលបិទនៅមុខការិយាល័យបោះឆ្នោត**







**អ្នកបោះឆ្នោតឈរតម្រង់ជួរដើម្បីចូលក្នុងការិយាល័យបោះឆ្នោត**

នៅពេលបានចូលក្នុងការិយាល័យបោះឆ្នោត អ្នកបោះឆ្នោតត្រូវទៅជួបលេខាធិការមុនគេ ។

- លេខាធិការត្រួតពិនិត្យម្រាមដៃអ្នកបោះឆ្នោត ដើម្បីបញ្ជាក់ឱ្យប្រាកដថា គ្មានស្នាមទឹកខ្មៅលុបមិនជ្រះ ។
- អ្នកបោះឆ្នោត ត្រូវប្រគល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតសម្គាល់ខ្លួនជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់នៅក្នុង

មុខតំណែង ឬឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោតឱ្យលេខាធិការ ដើម្បីពិនិត្យផ្ទៀងផ្ទាត់ឈ្មោះ និងទិន្នន័យពាក់ព័ន្ធនៅក្នុងបញ្ជីបោះឆ្នោត ។ ក្នុងករណីនេះ អ្នកបោះឆ្នោតត្រូវប្រាប់លេខរៀងរបស់ខ្លួនទៅលេខាធិការ ដើម្បីងាយស្រួលក្នុងការរកឈ្មោះក្នុងបញ្ជីបោះឆ្នោតបានលឿន ។







**លេខាធិការពិនិត្យផ្ទៀងផ្ទាត់ឈ្មោះ និងទិន្នន័យអ្នកបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត**







លេខាធិការប្រគល់សន្លឹកឆ្នោត ដែលមានពណ៌លឿង សម្រាប់ការបោះឆ្នោតជ្រើសរើស
ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងឯកសារបញ្ជាក់អត្តសញ្ញាណទៅអ្នកបោះឆ្នោត ។







អ្នកបោះឆ្នោតគូសសន្លឹកឆ្នោតក្នុងបន្ទប់សម្ងាត់ទី១
សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ







អ្នកបោះឆ្នោតស៊កសន្លឹកឆ្នោតចូលទៅក្នុងហិបឆ្នោត ដែលស្ថិតនៅលើតុអនុប្រធាន
(ហិបឆ្នោតបិទក្រដាសលេខកូដការិយាល័យបោះឆ្នោតពណ៌លឿង សម្រាប់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ)




អនុប្រធានប្រគល់សន្លឹកឆ្នោត ដែលមានពណ៌ស សម្រាប់ការបោះឆ្នោត
ជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ទៅអ្នកបោះឆ្នោត ។




អ្នកបោះឆ្នោតគូសសន្លឹកឆ្នោតនៅក្នុងបន្ទប់សម្ងាត់ទី២
សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត







**អ្នកបោះឆ្នោតស៊កសន្លឹកឆ្នោតចូលទៅក្នុងហិបឆ្នោត ដែលស្ថិតនៅលើតុសមាជិកទី១**
**(ហិបឆ្នោតបិទក្រដាសលេខកូដការិយាល័យបោះឆ្នោតពណ៌ស សម្រាប់ក្រុមប្រឹក្សារាជធានី ខេត្ត)**




អ្នកបោះឆ្នោតយល់ព្រមឱ្យសមាជិកទី១ ជ្រលក់ម្រាមចង្អុលដៃស្តាំ
ទៅក្នុងដបទឹកខ្មៅលុបមិនជ្រះ




អ្នកបោះឆ្នោតដើរចេញពីការិយាល័យបោះឆ្នោត


១
យើងត្រូវដឹងថា សន្លឹកឆ្នោតយើង
គឺជាសន្លឹកឆ្នោតសម្ងាត់ គ្មានជនណាម្នាក់ដឹងថា
យើងបោះឆ្នោតជូនគណបក្សនយោបាយណាមួយឡើយ ។
បើមានជនណាម្នាក់មកសួរយើងថា
បោះឆ្នោតឱ្យគណបក្សណាមួយនោះ យើងមិនត្រូវ
ប្រាប់គេឡើយ ព្រោះវាជាការសម្ងាត់របស់យើង។
២
អូ!.....ខ្ញុំយល់ហើយ !

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

តារាងចំនួនសមាជិកក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ

ចំនួនអ្នកបោះឆ្នោត និងការិយាល័យបោះឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា អាណត្តិទី៣ ឆ្នាំ២០១៩

| ល.រ | ឈ្មោះរាជធានី ខេត្ត | ចំនួន សមាជិកក្រុមប្រឹក្សា រាជធានី ខេត្ត | ចំនួន សមាជិកក្រុមប្រឹក្សា ក្រុង ស្រុក ខណ្ឌ | ចំនួន ឃុំ សង្កាត់ | ចំនួន អ្នកបោះឆ្នោត | ចំនួន ការិយាល័យ បោះឆ្នោត | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| 01 | បន្ទាយមានជ័យ | 25 | 169 | 65 | 515 | 9 | |
| 02 | បាត់ដំបង | 27 | 260 | 102 | 814 | 14 | |
| 03 | កំពង់ចាម | 27 | 204 | 109 | 817 | 10 | |
| 04 | កំពង់ឆ្នាំង | 23 | 140 | 70 | 422 | 8 | |
| 05 | កំពង់ស្ពឺ | 25 | 154 | 87 | 609 | 8 | |
| 06 | កំពង់ធំ | 25 | 169 | 81 | 577 | 9 | |
| 07 | កំពត | 25 | 148 | 93 | 561 | 8 | |
| 08 | កណ្ដាល | 27 | 221 | 127 | 915 | 11 | |
| 09 | កោះកុង | 19 | 87 | 29 | 167 | 7 | |
| 10 | ក្រចេះ | 21 | 108 | 47 | 295 | 6 | |
| 11 | មណ្ឌលគិរី | 15 | 59 | 21 | 107 | 5 | |
| 12 | ភ្នំពេញ | 27 | 270 | 105 | 899 | 14 | |
| 13 | ព្រះវិហារ | 19 | 112 | 51 | 333 | 8 | |
| 14 | ព្រៃវែង | 27 | 249 | 116 | 892 | 13 | |
| 15 | ពោធិ៍សាត់ | 21 | 121 | 49 | 343 | 7 | |
| 16 | រតនគិរី | 19 | 115 | 50 | 260 | 9 | |
| 17 | សៀមរាប | 27 | 216 | 100 | 668 | 12 | |
| 18 | ព្រះសីហនុ | 19 | 71 | 29 | 177 | 5 | |
| 19 | ស្ទឹងត្រែង | 17 | 80 | 34 | 176 | 6 | |
| 20 | ស្វាយរៀង | 23 | 140 | 80 | 518 | 8 | |
| 21 | តាកែវ | 27 | 192 | 100 | 736 | 10 | |
| 22 | កែប | 15 | 26 | 5 | 31 | 2 | |
| 23 | ប៉ៃលិន | 15 | 30 | 8 | 52 | 2 | |
| 24 | ឧត្ដរមានជ័យ | 19 | 77 | 24 | 152 | 5 | |
| 25 | ត្បូងឃ្មុំ | 25 | 137 | 64 | 536 | 7 | |
| | **សរុបទូទាំងប្រទេស** | **559** | **3,555** | **1,646** | **11,572** | **203** | |

ថ្ងៃច័ន្ទ ៧កើត ខែមាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែកុម្ភៈ ឆ្នាំ២០១៩